**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ :** ០១៤/២១ **ក.ប**/ស.ជ.ណ.ខ.ល

# សេចក្តីជូនដំណឹង
## ស្តីពី
## ការចាក់វ៉ាក់សាំងកូវីដ-១៩ (ស៊ីណូវ៉ាក់) ជូនបងប្អូនកម្មករ និយោជិតតាមរោងចក្រ សហគ្រាស នៅរាជធានីភ្នំពេញ

យោងអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលតែងតែមានទឹកចិត្តអាណិតស្រឡាញ់ចំពោះបងប្អូនកម្មករ និយោជិត និងការពារនូវសុខភាពនិងអាយុជីវិតរបស់បងប្អូនកម្មករ និយោជិត ក៏ដូចជាយោងការឯកភាពជាគោលការណ៍របស់ **លោកជំទាវប្រធាន** គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស និងយោងការណែនាំរបស់ **ឯកឧត្តម អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នោះអនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ជូនបងប្អូនកម្មករនិយោជិតបានចងក្រងគ្រូពេទ្យការងារ គ្រូពេទ្យប្រចាំរោងចក្រ និងគ្រូពេទ្យស្ម័គ្រចិត្តនានាបង្កើតជាក្រុមគ្រូពេទ្យចាក់វ៉ាក់សាំងចំនួន ៦០ក្រុម ដោយ ១ក្រុម មានគិលានុបដ្ឋាក និងគ្រូពេទ្យចំនួន ៨នាក់, អ្នកបញ្ចូលទិន្នន័យ និងអ្នកសម្របសម្រួលចំនួន ៧នាក់ និងមានសមត្ថភាពចាក់បានចំនួន ៤០០ដូស ក្នុងមួយថ្ងៃ។ ក្រុមគ្រូពេទ្យចាក់វ៉ាក់សាំងចំនួន ៣០ក្រុម នឹងចល័តចាក់វ៉ាក់សាំងចំនួន ២០ម៉ឺនដូស ក្នុងមួយខែ ជូនបងប្អូនកម្មករ និយោជិតនៅតាមរោងចក្រ សហគ្រាស នៅក្នុងដែនរាជធានីភ្នំពេញ។ ដោយឡែកក្រុមគ្រូពេទ្យចាក់វ៉ាក់សាំងចំនួន ៣០ក្រុមផ្សេងទៀត នឹងចល័តចាក់វ៉ាក់សាំងជូនបងប្អូនកម្មករនិយោជិតនៅតាមរោងចក្រ សហគ្រាស នៅតាមបណ្តាខេត្តផ្សេងទៀតតាមការចាំបាច់ និងតាមចំនួនវ៉ាក់សាំងដែលមាន។

ចំពោះមុខនេះ អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ជូនបងប្អូនកម្មករ និយោជិត សូមជូនដំណឹងដល់បងប្អូនកម្មករ និយោជិត និងម្ចាស់រោងចក្រ សហគ្រាស នៅក្នុងដែនរាជធានីភ្នំពេញ និងថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈនានាជ្រាបអំពីកាលបរិច្ឆេទ ទីតាំង និងយន្តការចាក់វ៉ាក់សាំងកូវីដ-១៩ (ស៊ីណូវ៉ាក់) ដូចខាងក្រោម៖

**ក. កាលបរិច្ឆេទចាប់ផ្តើម៖** ចាប់ពីថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១

**ខ. ទីតាំង**

**១. នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

សម្រាប់ចាក់ជូនថ្នាក់ដឹកនាំនិងបុគ្គលិករបស់សហព័ន្ធសហជីព សហភាពសហជីព សមាគមនិយោជក និងអង្គការវិជ្ជាជីវៈនានា។

**២. នៅតាមរោងចក្រ សហគ្រាស សួនឧស្សាហកម្ម និងតំបន់សេដ្ឋកិច្ចពិសេស**

សម្រាប់ចាក់ជូនកម្មករនិយោជិតខ្មែរ និងបរទេស នៅតាមរោងចក្រ សហគ្រាស ឬសួនឧស្សាហកម្ម ឬតំបន់សេដ្ឋកិច្ចពិសេស។ ថ្នាក់ដឹកនាំ និងបុគ្គលិករបស់សហជីពមូលដ្ឋាននៅតាមរោងចក្រ សហគ្រាស ឬអង្គភាពនីមួយៗ ត្រូវចាក់វ៉ាក់សាំងនៅតាមមូលដ្ឋានរោងចក្រ សហគ្រាស ឬអង្គភាពរបស់ខ្លួន។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ :(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

## គ. ការចុះឈ្មោះ

### ១. សម្រាប់ថ្នាក់ដឹកនាំ និងបុគ្គលិកនៃអង្គការវិជ្ជាជីវៈ

- គ្រប់សហព័ន្ធសហជីព សហភាពសហជីព សមាគមនិយោជក និងអង្គការវិជ្ជាជីវៈផ្សេងទៀត ត្រូវផ្តល់បញ្ជីឈ្មោះ (ឧបសម្ព័ន្ធ១) ថ្នាក់ដឹកនាំ និងបុគ្គលិករបស់ខ្លួន ដែលស្ម័គ្រចិត្តចាក់វ៉ាក់សាំងឱ្យបានយ៉ាងតិចចំនួន ៣ថ្ងៃ មុនកាលបរិច្ឆេទចាក់វ៉ាក់សាំង មកអនុគណៈកម្មការចំពោះកិច្ច តាមរយៈកម្មវិធី Telegram bot ដោយវាយនៅក្នុង Search នៃកម្មវិធី Telegram នូវពាក្យ "**unionvaccination_bot**" និងមានឈ្មោះផ្លូវការជាអក្សរខ្មែរនៅជួរខាងលើថា "បញ្ជីឈ្មោះថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ"
- ក្នុងករណីចាំបាច់ អាចទំនាក់ទំនង លោក ជ្រុន ថេរ៉ាវង្ស (017 987 261), លោក ហេង ប៊ុនថា (089 969 631), និងលោក យុត អ៊ួច (087 787 690)។

### ២. សម្រាប់កម្មករនិយោជិតខ្មែរ

- សាមីជនត្រូវចុះឈ្មោះជាមួយ រោងចក្រ សហគ្រាស ឬអង្គភាពរបស់ខ្លួន
- ម្ចាស់រោងចក្រ សហគ្រាស ឬអង្គភាព ត្រូវផ្តល់បញ្ជីឈ្មោះកម្មករ និយោជិត (ឧបសម្ព័ន្ធ២) ដែលស្ម័គ្រចិត្តចាក់វ៉ាក់សាំងកូវីដ-១៩ មកអនុគណៈកម្មការចំពោះកិច្ច តាមរយៈកម្មវិធី Telegram bot ដោយវាយនៅក្នុង Search នៃកម្មវិធី Telegram នូវពាក្យ "**employeevaccination_bot**" និងមានឈ្មោះផ្លូវការជាអក្សរខ្មែរនៅជួរខាងលើថា "បញ្ជីឈ្មោះកម្មករនិយោជិត"
- ក្រុមការងារកំណត់ទីតាំងនឹងជូនដំណឹងអំពីកាលបរិច្ឆេទពិតប្រាកដក្នុងការចុះទៅតាមរោងចក្រ សហគ្រាស ឬសួនឧស្សាហកម្ម ឬតំបន់សេដ្ឋកិច្ចពិសេស ឬតាមអង្គភាព ទៅតាមកម្រិតអាទិភាពនៃភូមិសាស្ត្រខណ្ឌនីមួយៗ និងដោយកំណត់អាទិភាពចុះទៅរោងចក្រ សហគ្រាស ឬសួនឧស្សាហកម្ម ឬតំបន់សេដ្ឋកិច្ចពិសេស ឬអង្គភាពណាមួយ ដែលមានចំនួនកម្មករ និយោជិតស្ម័គ្រចិត្ត ចាក់វ៉ាក់សាំងច្រើនមុន។

### ៣. សម្រាប់វិនិយោគិន ឬម្ចាស់ ឬអ្នកគ្រប់គ្រង ឬអ្នកជំនាញជាជនបរទេស

- សាមីជនត្រូវចុះឈ្មោះជាមួយ រោងចក្រ សហគ្រាស ឬអង្គភាពរបស់ខ្លួន និងត្រូវបំពេញ និងយល់ព្រមតាមលក្ខខណ្ឌដូចខាងក្រោម៖
  - ✓ មានលិខិតឆ្លងដែនដែលមានសុពលភាព
  - ✓ មានទិដ្ឋាការរស់នៅ និងធ្វើការស្របច្បាប់
  - ✓ មានបណ្ណ/សៀវភៅការងារជនបរទេស (Work Permit) ដែលចេញដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
  - ✓ ត្រូវចាក់វ៉ាក់សាំងនៅក្នុងរោងចក្រ សហគ្រាស ឬអង្គភាព ដូចកម្មករ និយោជិតខ្មែរ
  - ✓ ត្រូវចាក់ប្រភេទវ៉ាក់សាំង ដូចប្រភេទវ៉ាក់សាំង ដែលកម្មករនិយោជិតខ្មែរកំពុងចាក់នៅទីតាំងនោះ។
- ម្ចាស់រោងចក្រ សហគ្រាស ឬប្រធានអង្គភាព ត្រូវផ្តល់បញ្ជីឈ្មោះកម្មករ និយោជិតជាជនបរទេស (ឧបសម្ព័ន្ធ៣) ដែលត្រូវចាក់វ៉ាក់សាំង មកអនុគណៈកម្មការចំពោះកិច្ច តាមរយៈកម្មវិធី Telegram bot "**employeevaccination_bot**"។

ក្នុងករណីចាំបាច់ពាក់ព័ន្ធនឹងបញ្ជីឈ្មោះកម្មករ និយោជិតសូមទំនាក់ទំនង លោក លាង សុភ័គ (016 766 877), កញ្ញា ជា សោភា (098 411 723), និងកញ្ញា លឹម រតនៈលាភា (071 719 0808)។

### ៤. ភារកិច្ចផ្សេងៗ ពេលរង់ចាំកាលបរិច្ឆេទចាក់វ៉ាក់សាំង

ក្នុងខណៈពេលរង់ចាំ ក្រុមការងាររបស់អនុគណៈកម្មការចំពោះកិច្ច ជូនដំណឹងអំពីកាលបរិច្ឆេទពិតប្រាកដដែលត្រូវចាក់វ៉ាក់សាំង សូមថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ បងប្អូនកម្មករនិយោជិតខ្មែរ និងបរទេស ព្យាយាមចុះ

ឈ្មោះជាមួយកម្មវិធីចុះឈ្មោះរបស់ក្រសួងសុខាភិបាល **https://cambodia-vaccine.gov.kh** ដើម្បីទាញយក QR Code ជាមុន។

**ឃ. នៅថ្ងៃចាក់វ៉ាក់សាំង**

- ត្រូវមកតាមកាលបរិច្ឆេទ និងម៉ោងកំណត់ ដែលមាននៅក្នុងសេចក្តីជូនដំណឹងទៅរោងចក្រ សហគ្រាស ឬសួនឧស្សាហកម្ម ឬតំបន់សេដ្ឋកិច្ចពិសេស ឬអង្គភាពនីមួយៗ
- ពាក់អាវដៃខ្លី ឬអាវដែលងាយស្រួលក្នុងការចាក់វ៉ាក់សាំង
- សម្រាប់ជនជាតិខ្មែរត្រូវយក អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ឬសំបុត្រកំណើត ច្បាប់ដើម និងថតចម្លងឯកសារទាំងនោះក្នុងទំហំក្រដាស A4 ចំនួន ១សន្លឹក
- សម្រាប់ជនបរទេសត្រូវយក លិខិតឆ្លងដែន និងបណ្ណ/សៀវភៅការងារជនបរទេស ច្បាប់ដើម ដែលចេញដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងថតចម្លងឯកសារទាំង២ នេះ ក្នុងទំហំក្រដាស A4 ចំនួន ១សន្លឹក
- ត្រូវពាក់ម៉ាសជាប់ជាប្រចាំ និងស្តាប់តាមការណែនាំរបស់ក្រុមការងារចាក់វ៉ាក់សាំងនៅតាមទីតាំងនីមួយៗ
- យកចិត្តទុកដាក់ស្តាប់ និងអាននូវសេចក្តីណែនាំនានារបស់ក្រុមគ្រូពេទ្យ ឬរបស់ក្រសួងសុខាភិបាល ដែលមានផ្តល់ជូន ឬបិទ ឬចាក់ផ្សាយនៅក្នុងទីតាំងចាក់វ៉ាក់សាំងនីមួយៗ។

**ខ. ទីតាំងចាក់វ៉ាក់សាំងនៅសប្តាហ៍ទី២ នៃខែមេសា ឆ្នាំ២០២១**

សម្រាប់សប្តាហ៍ទី២ នៃខែមេសានេះ អនុគណៈកម្មការចំពោះកិច្ចនឹងបើកទីតាំងចាក់វ៉ាក់សាំងកូវីដ-១៩នៅ៖

- ថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១
  - ✓ សួនឧស្សាហកម្មកាណាឌីយ៉ា (ផ្លូវវែងស្រេង)
  - ✓ សួនឧស្សាហកម្ម ISI តំបន់រោងចក្រដំបូលខៀវ (ផ្លូវវែងស្រេង)
  - ✓ តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ (ផ្លូវជាតិលេខ ៤)។
- ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២១
  - ✓ សួនឧស្សាហកម្មវឌ្ឍនៈ ១ (ផ្លូវវែងស្រេង)
  - ✓ រោងចក្រសិនចូវ (ផ្លូវវែងស្រេង)
  - ✓ សួនឧស្សាហកម្មវឌ្ឍនៈ ២ (ផ្លូវជាតិលេខ ៣)
  - ✓ រោងចក្រ Marvel។

អាស្រ័យដូចបានជម្រាបជូនខាងលើសូមបងប្អូនកម្មករ និយោជិត ម្ចាស់រោងចក្រ សហគ្រាស ជាជនជាតិខ្មែរ និងបរទេស ថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ ព្រមទាំងសាធារណជនមេត្តាជ្រាបជាព័ត៌មាន និងសូមមេត្តាជួយផ្សព្វផ្សាយ ពន្យល់ និងជំរុញការចាក់វ៉ាក់សាំងកូវីដ-១៩ ឱ្យបានផុសផុល ដើម្បីធានានិងរក្សាសុខភាពនិងផលប្រយោជន៍របស់បងប្អូនកម្មករនិយោជិត និងសង្គមជាតិយើង ជាពិសេសឆាប់បានវិលត្រឡប់មករកភាពប្រក្រតីនៃជីវិតប្រចាំថ្ងៃរបស់យើងវិញ។

*ថ្ងៃ ចន្ទ ៨រោច ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤*

*រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ មេសា ឆ្នាំ២០២១*

**ជ.រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ និងជាប្រធានអនុគណៈកម្មការចំពោះកិច្ច**

**ចាក់វ៉ាក់សាំងកូវីដ-១៩ ជូនបងប្អូនកម្មករនិយោជិត**

**ហេង សួរ**

## ឧបសម្ព័ន្ធ១

### បញ្ជីឈ្មោះបុគ្គលិកសហភាពសហជីព/សហព័ន្ធសហជីពដែលស្ម័គ្រចិត្តចាក់វ៉ាក់សាំងកូវីដ-១៩

សហភាពសហជីព/សហព័ន្ធសហជីព ..........................................................................................................

លេខទូរស័ព្ទទំនាក់ទំនង ...................................................................

| ល.រ | ឈ្មោះជាភាសាខ្មែរ | ឈ្មោះជាអក្សរឡាតាំង | ភេទ | ថ្ងៃខែឆ្នាំកំណើត | លេខទូរស័ព្ទ |
|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 |
| 1 | ហេង កញ្ញា | HENG KANHA | ស | 05/09/1990 | 012 000 000 |
| 2 | | | | | |
| 3 | | | | | |

បានបញ្ចប់ត្រឹមលេខរៀងទី.......... (ឈ្មោះ .............. ភេទ.......)

..................ថ្ងៃទី............ខែ...............ឆ្នាំ២០២១

(ហត្ថលេខា និងត្រា សហភាពសហជីព/សហព័ន្ធសហជីព)

## ឧបសម្ព័ន្ធ២

### បញ្ជីឈ្មោះកម្មករនិយោជិតដែលស្ម័គ្រចិត្តចាក់វ៉ាក់សាំងកូវីដ-១៩

រោងចក្រ សហគ្រាស ..........................................................................................................

អាសយដ្ឋាន ..........................................................................................................................

លេខទូរស័ព្ទទំនាក់ទំនង ...................................................................

| ល.រ | ឈ្មោះជាភាសាខ្មែរ | ឈ្មោះជាអក្សរឡាតាំង | ភេទ | ថ្ងៃខែឆ្នាំកំណើត | លេខទូរស័ព្ទ |
|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 |
| 1 | ហេង កញ្ញា | HENG KANHA | ស | 05/09/1990 | 012 000 000 |
| 2 | | | | | |
| 3 | | | | | |

បានបញ្ចប់ត្រឹមលេខរៀងទី.......... (ឈ្មោះ .............. ភេទ.......)

..................ថ្ងៃទី............ខែ...............ឆ្នាំ២០២១

(ហត្ថលេខា និងត្រា រោងចក្រ សហគ្រាស)

ឧបសម្ព័ន្ធ៣

ក្រុមហ៊ុន.....................................................

## បញ្ជីសម្រង់ទិន្នន័យកម្មករនិយោជិតបរទេសដែលស្ម័គ្រចិត្តចាក់វ៉ាក់សាំងកូវីដ-១៩

**Personal Information Sheet *(For Foreigner Only)***

| ល.រ<br>No. | ឈ្មោះ<br>Full Name | ភេទ<br>Sex | ថ្ងៃខែឆ្នាំកំណើត<br>Date of Birth<br>(dd/mm/yyyy) | សញ្ជាតិ<br>Nationality | លេខលិខិតឆ្លងដែន<br>Passport Number | លេខទិដ្ឋាការ<br>Visa Number | លេខសៀវភៅ/បណ្ណការងារ<br>Work Permit Number |
|---|---|---|---|---|---|---|---|
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

..............................ថ្ងៃទី............ខែ...............ឆ្នាំ២០២១

(ហត្ថលេខា និងត្រា រោងចក្រ ឬសហគ្រាស)